**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៣៣ * ៤៤

**ក្រសួងមហាផ្ទៃ**

លេខ: ...

**ក្រសួងការងារ**
**និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# ប្រកាសអន្តរក្រសួង
# ស្តីពី
# នីតិវិធី និងបែបបទ នៃការចេញ
# លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស

៣៣ * ៤៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ/បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ១៩០ អនក្រ.បក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសតាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន
- បានឃើញអនុក្រឹត្យលេខ១៨៤ អនក្រ.បក ចុះថ្ងៃទី ១៦ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មចំណុះក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១២អនក្រ.បក ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស
- យោងតាមសំណូមពរចាំបាច់នៃការងារ។

**សម្រេច**

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកំណត់អំពីនីតិវិធី និងបែបបទ នៃការចេញ ការផ្តល់ ... បដិស្រ្តលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស សំដៅបង្កភាពងាយស្រួលដល់ពលករកម្ពុជា ... មាន

ឯកសារ សម្រាប់ធ្វើដំណើរឆ្លងដែនពី ព្រះរាជាណាចក្រកម្ពុជា ទៅកាន់ប្រទេសដែលពលករកម្ពុជាទទួលបានការអនុញ្ញាតឲ្យស្នាក់នៅ និងធ្វើការងារជាផ្លូវការ។

**ប្រការ ២.-**

ពលករកម្ពុជាទៅធ្វើការងារជាផ្លូវការនៅបរទេស សំដៅដល់ពលករ ដែលមានកិច្ចសន្យាការងារ និងមានការបញ្ជាក់ទទួលស្គាល់ដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈស្របតាមច្បាប់ជាធរមាន។

**ប្រការ ៣.-**

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ធ្វើប្រតិភូកម្មអំណាចជូន អគ្គនាយកដ្ឋានការងារដើម្បី៖

- ចេញឯកសារបញ្ជាក់ទទួលស្គាល់ពលករកម្ពុជាធ្វើការងារនៅបរទេស និងប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស ជូនពលករកម្ពុជា
- រៀបចំសំណុំបែបបទស្នើសុំលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេសជូនពលករកម្ពុជា បន្ទាប់ពីទទួលបានសំណុំឯកសារពីទីភ្នាក់ងារជ្រើសរើសឯកជន ឬពីពលករ ពលការិនី រយៈពេលយ៉ាងយូរ ០២ថ្ងៃនៃថ្ងៃធ្វើការ បញ្ជូនទៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មរបស់ក្រសួងមហាផ្ទៃ
- លើកសំណើទៅ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ចំណុះក្រសួងមហាផ្ទៃ ស្តីពី ការដកហូត ឬបដិសេធលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស ក្នុងករណីប្រើប្រាស់ខុសគោលដៅ ឬ ក្លែង ឬបាត់។

**ប្រការ ៤.-**

ក្រសួងមហាផ្ទៃ ធ្វើប្រតិភូកម្មភូកម្មអំណាចជូន អគ្គនាយកដ្ឋានអត្តសញ្ញាណកម្មដើម្បី៖

- ពិនិត្យសម្រេចផ្តល់លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេសជូនពលករកម្ពុជា តាមសំណុំឯកសារស្នើសុំរបស់អគ្គនាយកដ្ឋានការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ចេញលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស ក្នុងរយៈពេលយ៉ាងយូរ១៥ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីពលករបានបំពេញបែបបទត្រឹមត្រូវគ្រប់គ្រាន់ នៅនាយកដ្ឋានលិខិតឆ្លងដែន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម
- ដកហូត ឬបដិសេធលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស ក្នុងករណីប្រើប្រាស់ខុសគោលដៅ ឬក្លែងឬបាត់។

**ប្រការ ៥.-**

ពលករកម្ពុជា ដែលមានឈ្មោះក្នុងសំណុំឯកសារស្នើសុំ ផ្តល់លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស របស់អគ្គនាយកដ្ឋានការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវ៖

- បំពេញសំណុំបែបបទសុំផ្តល់លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស ដោយផ្ទាល់ ដូចជា៖ បំពេញពាក្យស្នើសុំផ្តល់លិខិតធ្វើដំណើរ ថតរូប ផ្តិតខ្ទាំ ម្រាមដៃ ចុះហត្ថលេខា វាស់កម្ពស់ និង យកភិនភាគស្លាកស្នាម

- ភ្ជាប់មកជាមួយនូវឯកសារច្បាប់ដើម ឬច្បាប់ថតចម្លងត្រឹមត្រូវតាមច្បាប់ដើមដូចខាងក្រោម៖

- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬសំបុត្រកំណើត និង
- សៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ ឬ
- ឯកសារបញ្ជាក់អត្តសញ្ញាណផ្សេងទៀតដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច។

**ប្រការ ៦.-**

ក្រសួងមហាផ្ទៃ និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ មានការកិច្ចរួមសហការជាមួយគ្នាដើម្បីជួយសម្រួលដល់ការបំពេញបែបបទផ្តល់ លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស និងប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស ជូនពលករកម្ពុជាដែលបាននឹងកំពុងស្នាក់នៅធ្វើការងារនៅបរទេស ហើយមិនទាន់មានឯកសារគ្រប់គ្រាន់តាមច្បាប់ ដើម្បីទទួលបានការអនុញ្ញាតឲ្យស្នាក់នៅ និងធ្វើការងារជាផ្លូវការ។

បែបបទដែលត្រូវអនុវត្តសម្រាប់ការចេញលិខិតធ្វើដំណើរនេះ ត្រូវបានកំណត់ដូចតទៅ៖

- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬសំបុត្រកំណើត និង សៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ
- ប័ណ្ណ ឬឯកសារដែលអនុញ្ញាតឲ្យធ្វើការងារ ដែលចេញដោយ អាជ្ញាធរមានសមត្ថកិច្ចរបស់ប្រទេសដែលពលករកម្ពុជាបាននឹងកំពុងស្នាក់នៅធ្វើការងារ
- បញ្ជីឈ្មោះពលករកម្ពុជា រៀបចំដោយមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយផ្អែកលើប័ណ្ណឬឯកសារដែលអនុញ្ញាតឲ្យធ្វើការងារដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចរបស់ប្រទេសនោះ
- ផ្តល់បង្កាន់ដៃជូនពលករ សម្រាប់ការទទួលយកលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស។

**ប្រការ ៧.-**

ត្រូវដកហូត ឬបដិសេធលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេសក្នុងករណី៖

- អ្នកដែលកាន់លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេសមិនមែនជាពលរដ្ឋខ្មែរ
- អ្នកដែលកាន់លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេសមិនមានប័ណ្ណពលករកម្ពុជាធ្វើការងារនៅបរទេស ឬមិនមានឈ្មោះក្នុងបញ្ជីសំណុំឯកសារស្នើសុំផ្តល់លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- អ្នកដែលកាន់កាប់ ឬប្រើប្រាស់លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស មិនមែនជាពលករកម្ពុជា ធ្វើការជាផ្លូវការនៅបរទេស តាមរយៈក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេសដែលក្លែង ឬបាត់។

**ប្រការ ៨.-**

ត្រូវទទួលទណ្ឌកម្មរដ្ឋបាល ឬ/និង ទទួលទោសតាមច្បាប់ជាធរមានចំពោះជនណាដែល៖

- ផ្តល់ព័ត៌មានខុសពីការពិតក្នុងសំណុំបែបបទសុំផ្តល់លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស
- ក្លែង កោស លុប ឬ សរសេរត្រួតលើលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស
- មានចេតនាជួយសម្រួលសំណុំបែបបទ ឬសម្រេចផ្តល់លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេសដល់ជនណាដែលមិនមែនជាពលករកម្ពុជាត្រូវទៅធ្វើការជាផ្លូវការនៅបរទេស។

**ប្រការ ៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ១០.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយក នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ អគ្គនាយក នៃអគ្គនាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនានា នៃក្រសួងមហាផ្ទៃ អគ្គនាយក នៃអគ្គនាយកដ្ឋានការងារ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ប្រធានអង្គភាពពាក់ព័ន្ធនានា នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២៣ ខែ [illegible] ឆ្នាំ២០១៥

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ស ខេង**

រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

**អ៊ិត សំហេង**

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ